# ១ កូរិនថូស ២ សេចក្តីអធិប្បាយ លោក ស៊ីម៉ូន ម៉ានឆេស្ទ័រ Simon Manchester

មនុស្សជាច្រើននៅក្នុងលោកចូលចិត្តនិយាយពីរឿងរ៉ាវ«ខាងវិញ្ញាណ»។ បញ្ហាលំបាកត្រង់ថា ប្រសិនបើម្នាក់ៗសុទ្ធតែមានសេចក្តីពិត «ខាងវិញ្ញាណ» របស់ខ្លួនឯងដែលខុសៗគ្នារៀងៗខ្លួន ហើយគ្រប់ៗគ្នាសុទ្ធតែមានវិធីផ្ទាល់ខ្លួនក្នុងការទៅស្ថានសួគ៌ នោះអ្នកនឹងមិនដឹងប្រាកដថាផ្លូវមួយណាត្រូវឬផ្លូវមួយណាខុសនោះឡើយ ឬថាអ្នកកំពុងតែបង្កើតសេចក្តីពិតរបស់ខ្លួនឡើង ដែលមានប្រយោជន៍តែបន្តិចបន្តួច បន្ទាប់មកបង្ករភាពវឹកវរនិងមិនអាចជួយអ្នកបានទាល់តែសោះ។ អ្វីដែលជាភាពល្អឯករបស់សាសនាគ្រីស្ទគឺនៅត្រង់សេចក្តីបង្រៀនថា ព្រះជាម្ចាស់បានចុះមកកាន់យើងរាល់គ្នា។ សាច់រឿងបុណ្យណូអែលបានសំដែងថា ព្រះជាម្ចាស់បានយាងមកកាន់យើងរាល់គ្នា ដើម្បីមិនចាំឲ្យយើងដុតចន្លុះ បំភ្លឺស្ថានសួគ៌ដើម្បីស្វែងរកទ្រង់នោះឡើយ។

កូរិនថូស ទី១ គឺជាសំបុត្ររបស់សាវកប៉ុលទៅកាន់ពួកជំនុំដែលមានអំណោយទានច្រើន ប៉ុន្តែមានបញ្ហាច្រើនផងដែរនោះគឺជាពួកជំនុំកូរិនថូសនៅក្នុងប្រទេសក្រិក។ នេះជាពួកជំនុំមួយប្រកបដោយទេពកោសល្យ និងពោពេញទៅដោយថាមពល។ តែជាពួកជំនុំមួយដែលធ្វើអោយក្តៅក្រហាយ ដ្បិតជាពួកជំនុំនៅក្មេងខ្ចី ហើយរឹងចចេសមិនទទួលយកការបង្រៀន។

ពួកជំនុំនេះបង្កើតឡើងដោយសាវកប៉ុល នៅក្នុងដំណើរបេសកកម្មមួយរបស់លោក ប៉ុន្តែក្រោយមកពួកជំនុំមានការប្រែប្រួលទាំងស្រុងតែម្តង។ ទស្សនៈថ្មីៗបានជ្រៀតចូលទៅក្នុងពួកជំនុំនេះ វាគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ ប៉ុន្តែវាផ្តោតសំខាន់ទៅលើការដាក់ខ្លួនឯងជាសំខាន់ ជាទី១។ ដូច្នេះសេចក្តីបង្រៀនអំពីឈើឆ្កាង និងការសុគតរបស់ព្រះគ្រីស្ទ ដែលធ្វើឲ្យពួកជំនុំនេះបានក្លាយជាគ្រួសាររបស់ព្រះជាម្ចាស់ បានក្លាយជាគំនិតចាស់គំរិល មិនទាន់សម័យសំរាប់ពួកគេទៅវិញ។ គ្រប់ទាំងសេចក្តីបង្រៀនថ្មីៗអំពីភាពជោគជ័យ និងក្តីអំណរដែលពួកគេមាន ធ្វើឲ្យគេគិតថា លោកប៉ុលគឺជាគ្រូបង្រៀនគួរឲ្យធុញថប់ហើយបានបង្រៀនសេចក្តីល្ងីល្ងើ។

ដូច្នេះគ្រីស្ទបរិស័ទនៅកូរិនថូស បានផ្លាស់ប្តូរនិងធ្វើឲ្យសាវកប៉ុលជួបការលំបាកពីព្រោះ លោកគឺជាអ្នកសង់ពួកជំនុំនេះឡើង ហើយទើបពេលនេះលោកត្រូវសរសេរសំបុត្រផ្ញើរទៅពួកគេ ដើម្បីកែតំរូវពួកគេ។ ពួកគេគិតថា ពួកគេបានរីកចំរើនទៅមុខហើយ តែតាមពិតពួកគេបានដើរថយក្រោយវិញទេ ហើយផ្ទុយពីការយកព្រះគ្រីស្ទជាចំនុចកណ្តាលនៃសេចក្តីស្រឡាញ់និងជំនឿរបស់គេ និងសម្រេចកាតព្វកិច្ចជាពន្លឺនៃលោកិយ ពួកគេក៏បានយកខ្លួនឯងជាចំនុចកណ្តាល បែងចែកបក្សពួក មើលទៅដូចជាមនុស្សឆ្កួតលីលា។

ការឆ្កួតលីលាមាន២ប្រភេទ៖ ពេលខ្លះពួកអ្នកមិនជឿមើលមកពួកអ្នកជឿហើយនិយាយថា «អ្នកនេះបាត់បង់ស្មារតីហើយ»។ ពេលខ្លះនៅពេលពួកគេនិយាយថា នេះពិបាកយល់នោះមិនដឹងថាតើពួកគេមានន័យថាពួកអ្នកជឿបានជឿសេចក្តីដែលអ្នកមិនជឿមិនអាចយល់បានទេ ឬថាពួកអ្នកជឿថ្មីគឺជាមនុស្សឆ្កួត និយាយគ្មានហេតុផល។

ចំនុចទី១ពិបាកចៀសវាងណាស់ ដ្បិតជាច្រើនដងពួកអ្នកមិនជឿតែងសំឡឹងមើលពួកអ្នកជឿ ហើយនិយាយថា «ហេតុអ្វីបានជាវណ្ណា ហ្មត់ចត់ចំពោះសាសនាគាត់យ៉ាងនេះ? កុំតឹងរឹងពេក»។ យើងមិនអាចជៀសវាងគំនិតបែបនេះនោះឡើយ។ ប៉ុន្តែយើងមិនត្រូវក្លាយជាមនុស្សឆ្កួតហើយនិយាយមិនដឹងអីនោះទេ។ គ្រប់ពេលជំនឿរបស់យើងត្រូវប្រកបដោយហេតុផល វិចារណញ្ញាណ មានន័យគ្រប់គ្រាន់និងប្រកបដោយភាពវាងវៃផងដែរ។ តាមពិតជំនឿរបស់យើងប្រកបដោយលក្ខណៈទាំងអស់នោះ។

នៅក្នុងជំពូក១ យើងបានឃើញហើយថា សាវកប៉ុលបានពន្យល់ថា ព្រះចេស្តារបស់ព្រះជាម្ចាស់មិនអាចមើលឃើញ ដោយមិននិយាយពីឈើឆ្កាងនោះឡើយ វាក៏មិនអាចរកឃើញតាមរយៈការយកវីរបុរស មកដាក់នៅមុខពួកជំនុំ ឬនៅមុខទំព័រទស្សនាវដ្តីឬសៀវភៅគ្រីស្ទបរិស័ទនោះឡើយ ហើយវាក៏មិនអាចរកឃើញតាមរយៈដាក់អ្នកកំប្លែងអធិប្បាយនៅក្នុងពួកជំនុំនោះដែរ។ ព្រះចេស្តារបស់ព្រះជាម្ចាស់នឹងសំដែងចេញ នៅពេលសារនៃឈើឆ្កាងត្រូវបានអធិប្បាយពន្យល់ ពួកជំនុំជួបជុំគ្នា ហើយអ្នកអធិប្បាយបានចែកចាយព្រះបន្ទូលយ៉ាងច្បាស់លាស់។

ជំពូក១:២៤ បានចែងថា «ព្រះគ្រីស្ទទ្រង់ជាព្រះចេស្តា»។ សាវកប៉ុលបានពន្យល់ថា យើងកំពុងនិយាយពីព្រះគ្រីស្ទដែលបានជាប់ឆ្កាង ទ្រង់ជាព្រះចេស្តានៃព្រះ។ ក្នុងករណីក្រែងលោពួកកូរិនថូស គិតថាសាវកប៉ុលជាមនុស្សឆ្កួតទើបនិយាយដូចនេះ នោះលោកបានបន្តទៀតនៅក្នុងជំពូក១:២៤ ដដែលថា «ព្រះគ្រីស្ទជាប្រាជ្ញារបស់ព្រះ»។ ឬអាចនិយាយបានម្យ៉ាងទៀតថា ពួកកូរិនថូសគិតថាពួកគេបានរកឃើញផ្លូវថ្មីមួយផ្សេងទៀត និងប្រសើរជាង ដែលបាននាំពួកគេឲ្យមានការរីកចំរើនខាងវិញ្ញាណ។ ពួកគេមានផ្លូវថ្មីមួយដើម្បីទៅជួបព្រះ

អង្គ ដូចនេះហើយទើបសាវកប៉ុលបានព្យាយាមកែតម្រូវពួកគេ ពីផ្លូវខុសនោះ ដោយប្រាប់ពួកគេពីសេចក្តីពិតអំពីព្រះវិញ្ញាណទ្រង់ និងអំពីប្រាជ្ញាខាងវិញ្ញាណរបស់ព្រះជាម្ចាស់។

ពួកកូរិនថូសបានគិតថា ពួកគេមានទ្វារមួយសំរាប់នាំពួកគេទៅដល់ប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។ ពួកគេគិតថា បានចូលទៅក្នុងតំបន់មួយពិសេសជាងមុន ពីព្រោះពេលនេះពួកគេកំពុងស្ថិតនៅក្នុងកន្លែងមួយដែល អស្ចារ្យជាងមុន។ សាវកប៉ុលបានមានប្រសាសន៍ថា នេះគឺជាសេចក្តីបង្រៀនមួយខុសឆ្គង។ លោកបានមានប្រសាសន៍នៅក្នុងជំពូក២:៦ ថា «យើងខ្ញុំក៏និយាយតាមប្រាជ្ញាដែរ ... ដែលត្រូវសាបសូន្យនោះទេ»។ ឬអាចនិយាយម្យ៉ាងទៀតបានថា ពួកកូរិនថូសបានទទួលនូវអ្វីមួយដែលនឹងរលាយបាត់ ហើយសាវកប៉ុលចង់ឲ្យពួកគេងាកបែរមករកប្រាជ្ញារបស់ព្រះ ដែលនឹងស្ថិតស្ថេរនៅអស់កល្បជានិច្ចវិញ។

ដូច្នេះសព្វថ្ងៃនេះ មនុស្សខ្លះនិយាយរឿងរ៉ាវទាក់ទងខាងវិញ្ញាណ ហើយក៏បង្កើតគំនិតផ្សេងៗទាក់ទងនឹងវិញ្ញាណដែរ។ សំណួរដែលយើងត្រូវសួរគឺ «តើនោះជាវិញ្ញាណរបស់ព្រះជាម្ចាស់ឬ?» ហើយ «តើការនេះនៅតែមានរហូតដល់សព្វថ្ងៃនេះឬ?»។

**យើងនឹងពិនិត្យមើលចំនុច៣យ៉ាង៖**

**១. ការមកដល់នៃប្រាជ្ញាពិតខាងវិញ្ញាណ**

**២. ការបោះពុម្ពផ្សាយពីប្រាជ្ញាពិតខាងវិញ្ញាណ**

**៣. សិទ្ធិអំណាចនៃប្រាជ្ញាពិតខាងវិញ្ញាណ**

**១. ការមកដល់នៃប្រាជ្ញាពិតខាងវិញ្ញាណ**

ខ៦ «យើងខ្ញុំក៏និយាយតាមប្រាជ្ញា»។

ខ៧ «សេចក្តីអាថ៌កំបាំងដ៏លាក់ទុក»។ ពីមុនមកវាមិនទាន់កើតឡើងទេ តែពេលនេះបានកើតឡើងហើយ។ អ្វីដែលពីដើមត្រូវបានគ្របបាំង ពេលនេះបានបើកសំដែងឲ្យឃើញហើយ។

តើប្រាជ្ញារបស់ព្រះជាម្ចាស់គឺជាអ្វី? ខ២ បានចែងថា «ទ្រង់ត្រូវឆ្កាង»។ ហេតុអ្វីបានជាព្រះគ្រីស្ទត្រូវឆ្កាងគឺជាប្រាជ្ញារបស់ព្រះជាម្ចាស់? ពីព្រោះវាគឺជាសារប្រាប់ដល់មនុស្ស ពីរបៀបដែលពួកគេអាចផ្សះផ្សារជាមួយនឹងព្រះជាម្ចាស់។ តើអ្នកចង់ដឹងពីរបៀបក្នុងការប្រាស្រ័យទាក់ទងជាមួយព្រះជាម្ចាស់ទេ? មែនហើយ យើងអាចទាក់ទងជាមួយព្រះជាម្ចាស់តាមរយៈ*ព្រះគ្រីស្ទដែលបានជាប់ឆ្កាង* ពីព្រោះនៅពេលអ្នកយល់ពីមូលហេតុដែលព្រះគ្រីស្ទបានសុគត នោះអ្នកនឹងមើលឃើញថាព្រះគ្រីស្ទបានបើកទ្វារសំរាប់អស់ពួកអ្នកដែលជឿ។

យើងមិនអាចទាក់ទងជាមួយព្រះជាម្ចាស់ តាមរយៈទស្សនៈ បច្ចេកទេស ការឆ្នៃប្រឌិត ឬពិធីខាងសាសនារបស់មនុស្សនោះឡើយ។ វិធីតែមួយគត់ដែលយើងអាចទាក់ទងជាមួយនឹងព្រះជាម្ចាស់បាន គឺតាមរយៈការយាងមករបស់ទ្រង់ ដោយការសុគតរបស់ព្រះគ្រីស្ទជំនួសយើង។ ដំណោះស្រាយចំពោះការបដិសេធនិងការភាន់ច្រលំរបស់លោកិយនេះចំពោះព្រះជាម្ចាស់ គឺមិនស្ថិតនៅលើការគិតពិចារណា និងសមិទ្ធផលរបស់យើងនោះទេ តែស្ថិតនៅលើការយល់ដឹងរបស់យើងចំពោះអ្វីដែលព្រះជាម្ចាស់បានធ្វើ តាមរយៈព្រះយេស៊ូវគ្រីស្ទវិញ។ ទ្រង់បានយាងមកផែនដីដើម្បីយើង ហើយទ្រង់បានទទួលរងនូវទណ្ឌកម្មរបស់យើង គឺទទួលយកសេចក្តីស្លាប់របស់យើងដាក់នៅលើអង្គទ្រង់។

អ្នកណាខ្លះដែលជឿថា ប្រាជ្ញាខាងវិញ្ញាណដ៏ពិតនេះបានមកដល់ហើយ? ខ៨ បានចែងថា «គ្មានចៅហ្វាយណាក្នុងលោកិយនេះ...»។ ពួកអ្នកដឹកនាំក្នុងសម័យរបស់ព្រះយេស៊ូវ បានកាត់ព្រះយេស៊ូវចេញពីពួកគេ ហើយសព្វថ្ងៃនេះ យើងមិនអាចកាត់ព្រះយេស៊ូវចេញដោយការឆ្កាងទ្រង់នោះទេ តែអ្នកផ្ទាល់អាចកាត់ទ្រង់ចេញដោយគេចចេញពីទ្រង់ ឬមិនចូលចិត្តទ្រង់ ឬធ្វើព្រងើយកន្តើយចំពោះទ្រង់។ ប្រសិនបើអ្នកកាត់ព្រះគ្រីស្ទចេញពីគំនិត ពីជីវិត ឬពីផែនការណ៍របស់អ្នក នោះអ្នកនឹងបាត់បង់នូវប្រាជ្ញារបស់ព្រះជាម្ចាស់មិនខាន។

ខ៦ បានលើកឡើងពីក្រុមមួយផ្សេងទៀត ដែលអាចបាត់បង់នូវប្រាជ្ញារបស់ព្រះជាម្ចាស់ ពួកគេជាគ្រីស្ទបរិស័ទមិនមានភាពពេញវ័យ ឬគ្រប់លក្ខណ៍។ សាវកប៉ុលបានលើកឡើងថា «នៅក្នុងចំណោមមនុស្សគ្រប់លក្ខណ៍ នោះយើងខ្ញុំក៏និយាយ»។ ពួកកូរិនថូស គឺជាពួកអ្នកជឿ តែពួកគេបានប្រព្រឹត្តិកំហុសដោយគិតដូចកូនក្មេង។ ពួកកូរិនថូសគឺជាគ្រីស្ទបរិស័ទពិតប្រាកដ ហើយជីវិតរបស់ពួកគេមិនបានដាច់

ចេញពីព្រះគ្រីស្ទឡើយ ប៉ុន្តែពួកគេបានបាត់បង់ការរីកចំរើននៅក្នុងទ្រង់វិញ។ នេះគួរឲ្យសោកស្ដាយណាស់ ដ្បិតមនុស្សម្នាក់បានចាប់កំណើតហើយ តែបែរជាមិនមានការរីកធំធាត់ទៅវិញ។

ផ្ទុយពីការក្លាយជាមនុស្សគ្រប់លក្ខណ៍ដូចដែលមានចែងនៅក្នុងខ៦ ពួកគេនៅជាកូនខ្ចី (៣:១)។ នៅក្នុងពួកជំនុំតែងមានសមាជិកដែលប្រៀបបាននឹងកូនក្មេងដែលទើបតែរៀនដើរ និងខ្លះទៀតជាមនុស្សគ្រប់លក្ខណ៍។ មានន័យថា អ្នកខ្លះបានចាប់ផ្ដើមជីវិតគ្រីស្ទបរិស័ទរបស់ពួកគេ តែមើលទៅដូចជាមិនបានរីកចំរើនសោះ តែមានអ្នកខ្លះទៀតដែលបានចាប់ផ្ដើមជីវិតគ្រីស្ទបរិស័ទ ហើយបានរីកចំរើននៅក្នុងការយល់ដឹង និងការស្គាល់ព្រះអង្គ និងជីវិតបរិសុទ្ធ។

ព្រះជាម្ចាស់បានបើកសំដែងប្រាជ្ញារបស់ព្រះយេស៊ូវគ្រីស្ទនេះឲ្យមនុស្សទាំងអស់បានឃើញ ប៉ុន្តែវាជារឿងអស្ចារ្យមួយក្នុងការចាប់យកប្រាជ្ញានេះ។ នៅក្នុងខ១០ ព្រះគម្ពីរបានចែងថា «ព្រះទ្រង់បានសំដែង...»។

ពិនិត្យមើលខ្លួនអ្នកផ្ទាល់៖ តើសារពីព្រះគ្រីស្ទជាប់ឆ្កាងមានន័យសំខាន់សំរាប់អ្នកដែរឬទេ? តើសារនេះបានផ្លាស់ប្ដូរជីវិតអ្នកដែរឬទេ? តើអ្នកបានមើលឃើញថា សារនេះគឺជាផ្លូវនាំទៅកាន់គ្រួសាររបស់ព្រះជាម្ចាស់ឬទេ? ប្រសិនបើចំលើយរបស់អ្នកគឺជា «បាទ» នោះវាគឺជាការអស្ចារ្យមួយ។ ប៉ុន្តែមានសំណួរមួយទៀតសួរថា «ប្រសិនបើអ្នកមើលឃើញថា ព្រះគ្រីស្ទបានជាប់ឆ្កាងគឺជាផ្លូវទៅកាន់គ្រួសាររបស់ព្រះជាម្ចាស់ តើអ្នកនៅតែរាប់ប្រសាសន៍អំពីព្រះគ្រីស្ទដែលទ្រង់ត្រូវឆ្កាងជាប្រសាសន៍សំខាន់បំផុតនិងជាគ្រឹះនៃជំនឿឬទេ? ពួកកូរិនថូស បានលើកឡើងថា «យើងអាចបំភ្លេចការនោះចោល»។ ប៉ុន្តែត្រូវចាំថា ព្រះគ្រីស្ទបានជាប់ឆ្កាង គឺនៅតែជាប្រាជ្ញារបស់ព្រះចំពោះគ្រីស្ទបរិស័ទគ្រប់លក្ខណ៍ ដូចជាសោទ្វារ ដែលសំខាន់សំរាប់អ្នកក្នុងការចូលផ្ទះដូច្នោះដែរ។ អ្នកមិនដែលចាក់សោរបើកទ្វារហើយ បោះកូនសោចោលនោះទេ។ អ្នកតែងបើកទ្វារហើយ ចូលទៅក្នុងផ្ទះហើយទុកកូនសោយ៉ាងប្រុងប្រយ័ត្ន ពីព្រោះវាសំខាន់គ្រប់ពេលសំរាប់អ្នក។ សារពីព្រះគ្រីស្ទបានជាប់ឆ្កាងគឺមានសារៈសំខាន់ណាស់ចំពោះគ្រីស្ទបរិស័ទគ្រប់រូប។ សារនេះពន្យល់ពីព្រះគម្ពីរទាំងមូល ពីផែនការណ៍របស់ព្រះជាម្ចាស់ ពីរបៀបក្នុងការប្រាស្រ័យទាក់ទងជាមួយព្រះជាម្ចាស់ និងពីរបៀបដែលព្រះជាម្ចាស់បានអត់ទោសបាបឲ្យយើងផង។ លើសពីនេះវាក៏បានពន្យល់ពីរបៀបធ្វើឲ្យមានជីវិតអស់កល្បជានិច្ច និងពីរបៀបក្នុងការចែកចាយដំណឹងល្អដល់លោកិយនេះផងដែរ។

ពួកកូរិនថូសបានត្រលប់ជាមិនគ្រប់លក្ខណ៍ ដោយព្រោះតែពួកគេបានឈប់ផ្ដោតសំខាន់ទៅលើព្រះគ្រីស្ទដែលទ្រង់បានជាប់ឆ្កាង គឺជាប្រាជ្ញារបស់ព្រះជាម្ចាស់។នោះគឺជាការមកដល់ នៃប្រាជ្ញាពិតប្រាកដខាងវិញ្ញាណ។

**២. ការបោះពុម្ពផ្សាយពីប្រាជ្ញាពិតខាងវិញ្ញាណ**

ការបោះពុម្ពផ្សាយគឺជាកត្តាដ៏សំខាន់បំផុត សំរាប់អ្នកករនិពន្ធ។ ព្រះជាម្ចាស់គឺជាអ្នករៀបចំតាក់តែងសៀវភៅឡើង។ ព្រះគម្ពីរគឺជាសៀវភៅដ៏អស្ចារ្យបំផុតមួយពីព្រោះព្រះគម្ពីរ ត្រូវបានតាក់តែងឡើងដោយអ្នកនិពន្ធប្រមាណជាង៤០នាក់ ដែលបានសរសេរឡើងនៅក្នុងទ្វីប៣ខុសគ្នា ក្នុងរយៈពេលប្រមាណជាង២០០០ឆ្នាំនៅក្នុងប្រវត្តិសាស្ត្រ ជាបីភាសា ហើយទោះបីជាពួកគេមិនអាចមើលឃើញពីអ្វីដែលអ្នកដទៃទៀត បានសរសេរក្ដី តែយើងបានមើលឃើញថា ពួកអ្នកនិពន្ធដែលស្ថិតនៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់ គឺសុទ្ធតែបាញ់ឆ្ពោះទៅកាន់ព្រះគ្រីស្ទដូចគ្នាទាំងអស់។ ដូច្នេះនេះគឺជាសៀវភៅដ៏អស្ចារ្យបំផុតមួយ។

នៅក្នុងខ១០-១៣ សាវកប៉ុលបានពន្យល់ថា ជំនឿរបស់គ្រីស្ទបរិស័ទមិនមែនឆ្កួតលីលានោះទេ តែមានមូលដ្ឋានស្ថិតនៅលើព្រះបន្ទូលជាលាយលក្ខណ៍អក្សររបស់ព្រះជាម្ចាស់វិញ។ នៅពេលគ្រីស្ទបរិស័ទខ្លះនិយាយពីជីវិតរបស់ខ្លួន និងរឿងរ៉ាវខាងវិញ្ញាណរបស់ពួកគេ នោះជារឿយៗតែងតែមានភាពស្រពិចស្រពិលទាំងអស់។ នៅពេលខ្លះអ្នកបានឮគ្រីស្ទបរិស័ទខ្លះ និយាយពីរឿងខាងវិញ្ញាណ ហើយពួកគេគិតថា ពួកគេគឺជាមនុស្សខាងវិញ្ញាណល្អជាងគ្រីស្ទបរិស័ទឯទៀត។ តែនៅពេលយើងស្ដាប់ពួកគេនិយាយ នោះយើងមិនយល់ទាល់តែសោះ។ នេះគឺជាអត្តសញ្ញាណរបស់ពួកកូរិនថូស។ ពួកកូរិនថូស បានបោកបញ្ឆោតខ្លួនឯង ដោយនិយាយពីរឿងរ៉ាវទាក់ទងខាងវិញ្ញាណ ហើយពួកគេយល់ថាពួកគេមានការយល់ដឹងខាងវិញ្ញាណខ្ពស់ជាងអ្នកឯទៀត។ នេះគឺជាការមួយដែលធ្វើឲ្យមនុស្សជាច្រើនឆ្ងល់យ៉ាងខ្លាំងក្នុងនោះរួមទាំងសាវកប៉ុលដែរ។

នៅក្នុងខ១០-១៣ សាវកប៉ុលបានពន្យល់ថា ព្រះជាម្ចាស់បានធ្វើការដែលសំខាន់បំផុត។ ទ្រង់បានបោះពុម្ពសៀវភៅមួយក្បាលដែលគ្រប់គ្នាអាចអានបាន ហើយក៏មានន័យដែរថា មិនមានអ្នកណាម្នាក់អាចអួត ឬខកចិត្តអំពីរឿងរ៉ាវខាងវិញ្ញាណនោះឡើយ។

ចូរស្រមើស្រមៃថា នៅទីនេះមានសាស្ត្រាចារ្យដ៏ល្បីល្បាញម្នាក់ គាត់បានសំរេចចិត្តថា នឹងបោះពុម្ពសៀវភៅមួយក្បាល ដូច្នេះតើគាត់នឹងធ្វើអ្វីខ្លះ? មាន៤ដំណាក់កាលដែលគាត់ត្រូវធ្វើ។ ទីមួយ គាត់ត្រូវស្រាវជ្រាវអ្វីៗគ្រប់យ៉ាងឲ្យត្រូវនឹងប្រធានបទរបស់គាត់។ ទីពីរ គាត់ត្រូវរៀបរៀងអត្ថបទទាំងនោះទៅតាមលំដាប់លំដោយរបស់វា។ ទីបី គាត់ប្រើអ្នកណាម្នាក់ឲ្យយកអត្ថបទនោះទៅបោះពុម្ព។ ទីបួន គាត់យកសៀវភៅនោះទៅថ្នាក់រៀនរបស់គាត់ ហើយបង្រៀនមេរៀនចេញពីសៀវភៅនោះ។ នេះដូចអ្វីបេះបិទ ដែលព្រះវិញ្ញាណបានធ្វើ ដូចដែលយើងបានឃើញនៅក្នុងខ១០-១៣។ ដំណាក់កាលទាំងបួនដែលមានចែងនៅក្នុងខ១០គឺ «ព្រះវិញ្ញាណនៃទ្រង់ស្ទង់មើល...»។ ព្រះវិញ្ញាណរបស់ព្រះស្ទង់មើលពីព្រះទ័យរបស់ព្រះជាម្ចាស់។ ក្រៅពីខ្លួនឯង គ្មានអ្នកណាម្នាក់អាចយល់ពីជំរៅចិត្តរបស់យើងបានឡើយ ដូចគ្នានឹងព្រះជាម្ចាស់ដែរ ក្រៅពីវិញ្ញាណរបស់ព្រះជាម្ចាស់ នោះតើអ្នកណាអាចយល់ ពីព្រះជាម្ចាស់ដ៏មើលពុំឃើញបាន?

ខ១៣ «ព្រះវិញ្ញាណបង្រៀន...»។ ទ្រង់បានប្រមូលផ្តុំសំភារៈរបស់ទ្រង់។ នៅក្នុងខ១៣ក «យើងក៏និយាយ...» មានន័យថាយើងបានបោះពុម្ពនូវអ្វីៗ ដែលទ្រង់បានប្រាប់យើងឲ្យធ្វើ។ ទីបួននៅក្នុងខ១២ ព្រះបានផ្តល់មកយើង មានន័យថាព្រះវិញ្ញាណបានស្ទង់មើលពីព្រះជាម្ចាស់ ចងក្រងរឿងរ៉ាវគ្រប់យ៉ាងតាមលំដាប់រៀង បោះពុម្ពរឿងរ៉ាវទាំងអស់នោះតាមរយៈកវីនិពន្ធដែលជាមនុស្ស បន្ទាប់មកបង្រៀនពួកគេ នៅពេលណាបណ្តាជនចង់ស្វែងយល់ពីព្រះជាម្ចាស់។

នៅថ្ងៃលៀងព្រះអម្ចាស់ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ថា ខ្ញុំនឹងឃ្លាតទៅ ខ្ញុំនឹងត្រូវស្លាប់ ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធនឹងយាងមក ហើយនិងជួយអ្នកឲ្យចងចាំនូវការពីរយ៉ាង៖ ទីមួយជួយពួកសាវកឲ្យចងចាំនូវអ្វីៗដែលខ្ញុំបានមានបន្ទូល ហើយទីពីរ គឺចងចាំនូវអ្វីៗដែលនឹងកើតឡើង»។ ប្រសិនបើអ្នកចង់ដឹងពីរបៀបដែលពួកសិស្សទាំង១១បានចងចាំនូវអ្វីៗ ដែលព្រះយេស៊ូវបានមានបន្ទូល ជាពិសេសព្រះបន្ទូលដ៏វែងរបស់ទ្រង់ នោះចំលើយគឺមាននៅត្រង់នេះស្រាប់។ ព្រះវិញ្ញាណបរិសុទ្ធបានជួយពួកសិស្សឲ្យចងចាំនិងកត់ត្រានូវហេតុការណ៍ទាំងឡាយ។

ហេតុនេះសៀវភៅព្រះគម្ពីរ គឺជាព្រះបន្ទូលរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណបរិសុទ្ធមិនបានធ្វើកិច្ចការដាច់ដោយឡែកតែឯងនោះទេ គឺទ្រង់បានប្រើព្រះបន្ទូលនេះ។ ដូច្នេះ ការកែទម្រង់លេចជារូបរាងឡើង ដោយព្រោះមនុស្សតែម្នាក់ បានស្រាវជ្រាវព្រះបន្ទូលព្រះឡើងវិញ។ នៅពេលមនុស្សច្រើននៅក្នុងប្រទេសអង់គ្លេសបានជឿលើព្រះគ្រីស្ទ ក្រោមការដឹកនាំរបស់លោកវ៉េសលី និងលោកវ៉ាយហ្វៀល មិនមែនដោយសារព្រះវិញ្ញាណបរិសុទ្ធធ្វើការតែម្នាក់ឯងនោះទេ តែដោយសារមនុស្សនាំគ្នាក្រោកឈរ ហើយបានអធិប្បាយខ្លាំងៗថា «អ្នកត្រូវការការកើតម្តងទៀត»។ ពួកគេបានប្រើព្រះបន្ទូលរបស់ព្រះ ហើយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានប្រទានពរទៅលើព្រះបន្ទូលនោះដោយអំណាច។

នេះសំខាន់ណាស់ ដូចគ្នានឹងពួកជំនុំសព្វថ្ងៃនេះដែរ ដែលយល់ថា អ្នកអាចដើរតាមព្រះវិញ្ញាណ ហើយថាព្រះវិញ្ញាណនឹងនាំអ្នកទៅកាន់កន្លែងថ្មីៗ ដែលនៅឯនាយនៃព្រះបន្ទូលរបស់ទ្រង់។ ប៉ុន្តែព្រះគម្ពីរបានបង្រៀនយើងម្តងហើយម្តងទៀតថា ប្រសិនបើអ្នកដើរតាមព្រះវិញ្ញាណបរិសុទ្ធ នោះទ្រង់នឹងនាំអ្នកមកមើលព្រះបន្ទូលទ្រង់វិញ។ ទ្រង់នឹងនាំអ្នកឲ្យសិក្សាយ៉ាងស៊ីជំរៅនៅក្នុងសៀវភៅរបស់ទ្រង់។ អ្នកមិនអាចដើរតាមព្រះវិញ្ញាណ តែទុកព្រះគម្ពីរចោលមួយអន្លើនោះឡើយ។ ប្រសិនបើអ្នកដើរតាមព្រះវិញ្ញាណបរិសុទ្ធ  នោះអ្នកដឹងខ្លួនឯងថា អ្នកកំពុងតែចូលកាន់តែជ្រៅទៅៗ ទៅក្នុងព្រះគម្ពីរ។

ប្រាជ្ញាពិតប្រាកដខាងវិញ្ញាណ បានមកដល់ហើយ ហើយក៏បានបោះពុម្ពហើយដែរ និងមានមនុស្សជាច្រើនបានពេញចិត្តចំពោះសៀវភៅនេះ (ព្រះគម្ពីរ) ជាពិសេសពួកអ្នកដែលបានទទួលព្រះគ្រីស្ទ។ ប៉ុន្តែទោះបីជាអ្នកមិនបានទទួលព្រះគ្រីស្ទក៏ដោយ ក៏ព្រះគម្ពីរនៅតែជាសៀវភៅដ៏សំខាន់បំផុតមួយដែលគួរតែអាន ហើយខ្ញុំសូមលើកទឹកចិត្តគ្រប់គ្នាឲ្យអាន មិនថាអ្នកនៅក្នុងស្ថានភាពបែបណានោះទេ ពីព្រោះនៅពេលអ្នកអាន នោះអ្នកនឹងបានឃើញសេចក្តីពិតពីព្រះគ្រីស្ទ។

**៣. សិទ្ធិអំណាចនៃប្រាជ្ញាពិតខាងវិញ្ញាណ**

សាវកប៉ុលចង់ឲ្យពួកកូរិនថូសដឹងថា ពួកគេមិនមែនជាក្រុមមួយដែលពិសេសជាងគ្រីស្ទបរិស័ទដទៃទៀតនោះឡើយ។ តាមពិតពួកគេកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ដ្បិតបានបាត់បង់នូវសេចក្តីពិតដែលថា មានតែមនុស្សពីរពួកប៉ុណ្ណោះនៅក្នុងលោកិយនេះ នៅចំពោះព្រះជាម្ចាស់ ដែលជាមនុស្សគ្មានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ (ខ១៤) ឯនៅក្នុងទី១៥វិញ និយាយពីមនុស្សខាងវិញ្ញាណ។ ដូច្នេះ

មានន័យថា មានពួកអ្នកដែលនៅជាមួយនឹងព្រះគ្រីស្ទ និងពួកអ្នកដែលឥតមានព្រះគ្រីស្ទ។ ពួកគ្រីស្ទបរិស័ទគ្រាន់តែជាមនុស្សដែលជឿលើដំណឹងល្អប៉ុណ្ណោះ ហើយគេបានទទួលព្រះគ្រីស្ទតាមរយៈជំនឿ។ ប៉ុន្តែប្រសិនបើអ្នកចង់និយាយពីជីវិតគ្រីស្ទបរិស័ទរបស់អ្នកជាមួយនឹងអ្នកដទៃទៀត នោះអ្នកមិនត្រូវមានការភ្ញាក់ផ្អើលនោះទេ ប្រសិនបើមានការពិបាកយល់ចំពោះពួកគេ។ នៅក្នុង ខ១៤បានចែងថា «មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងឯ ព្រះវិញ្ញាណនៃព្រះទេ» មានន័យថា មានអ្នកខ្លះនឹងមិនចង់និយាយពីព្រះយេស៊ូវ ហើយមានអ្នកខ្លះទៀតគិតថា «ខ្ញុំមិនដឹងថាអ្នកកំពុងនិយាយពីអ្វីនោះទេ ខ្ញុំគិតថាអ្វីដែលអ្នកកំពុងតែនិយាយឥតមានប្រយោជន៍ទេ»។

ខ១៥ បានចែងថា «មនុស្សខាងវិញ្ញាណ...» មានន័យថា គ្រីស្ទបរិស័ទដែលបានទទួលអំណោយទានមើលឃើញពីប្រាជ្ញារបស់ព្រះជាម្ចាស់ នោះពេលនេះអាចមើលឃើញគ្រប់ទាំងអស់តាមរយៈដំណឹងល្អ។ បុគ្គលដែលមិនមែនជាគ្រីស្ទបរិស័ទ មិនអាចយល់ពីដំណឹងល្អនោះទេ តែបុគ្គលដែលបានត្រលប់ជាគ្រីស្ទបរិស័ទហើយ អាចមើលឃើញពីឆាកជីវិតទាំងស្រុងតាមរយៈព្រះគ្រីស្ទបាន។

សេចក្តីពិតអំពីប្រាជ្ញាពិតខាងវិញ្ញាណ ផ្តោតសំខាន់ទៅលើព្រះគ្រីស្ទ និងកិច្ចការនៃការសង្គ្រោះរបស់ទ្រង់មកដល់យើងរាល់គ្នា ដែលនេះគឺជាផ្ទៃរឿងនៃព្រះគម្ពីរទាំងមូល។ ប្រាជ្ញានេះបានមកដល់ហើយ បានបើកសំដែងឲ្យឃើញហើយ តែអ្នកនៅតែត្រូវការជំនួយដើម្បីឲ្យអាចយល់បាន អ្នកត្រូវការការប្តេជ្ញាចិត្តខ្ពស់ជាមួយនឹងព្រះគ្រីស្ទ ទើបអាចយល់បាន។ អ្នកត្រូវការវិលបែរទៅឯព្រះគ្រីស្ទ មិនត្រូវគេចចេញពីទ្រង់ឡើយ នោះទ្រង់នឹងជួយអ្នកមិនខាន។ ព្រះគម្ពីរត្រូវបានបោះពុម្ពផ្សាយ ជាសៀវភៅដ៏អស្ចារ្យមួយក្បាល។ ត្រូវប្រយ័ត្នចំពោះពួកអ្នកដែលមករកអ្នក ទោះបីជាអ្នកនោះជាមិត្តជិតស្និត ឬសាច់ញាតិក្តី ដោយនិយាយថា «ខ្ញុំមានសារពីព្រះជាម្ចាស់មក ទ្រង់មានបន្ទូលយ៉ាងនេះមួយ ឬយ៉ាងនោះមួយ» តែសារនេះមិនមាននិយាយនៅក្នុងព្រះគម្ពីរទេ។ មនុស្សបែបនោះមិនបានមកជួយអ្នកទេ តែផ្ទុយទៅវិញអ្នកនោះបានមកបោកប្រាស់អ្នកវិញ ពួកគេបានបោះបង់ចោលផ្លូវរបស់ព្រះអម្ចាស់ហើយ។ នៅពេលព្រះជាម្ចាស់មានបន្ទូល ទ្រង់មានបន្ទូលតាមរយៈព្រះបន្ទូលរបស់ទ្រង់ នោះជារបៀប ដែលទ្រង់បានសន្យាមានបន្ទូលមកកាន់រាស្ត្ររបស់ទ្រង់។ ខ្ញុំមិនបាននិយាយថាទ្រង់មិនអាចមានបន្ទូលនោះទេ ប្រសិនបើទ្រង់សព្វព្រះទ័យទ្រង់អាចមានបន្ទូលតាមរយៈមេឃ ឬដាស់មនុស្សតាមរយៈការយល់សុបិន្តណាមួយ ឬតាមរយៈសោកនាដកម្ម ឬរឿងរ៉ាវផ្សេងៗ។ ប៉ុន្តែប្រសិនបើទ្រង់សព្វព្រះទ័យប្រទានសេចក្តីសន្យាឲ្យអ្នក នោះនឹងធ្វើឡើងតាមរយៈព្រះបន្ទូលទ្រង់ដែលមាននៅក្នុងព្រះគម្ពីរជាមិនខាន។

ជាចុងក្រោយ ព្រះបន្ទូលរបស់ទ្រង់មានអំណាចណាស់។ ព្រះបន្ទូលប្រៀបបាននឹងវ៉ែនតាមួយគូរ ដែលយើងអាចឆ្លុះមើលពិភពលោក។ ព្រះជាម្ចាស់ទ្រង់ល្អចំពោះយើងណាស់! ទ្រង់មិនគ្រាន់តែសង្គ្រោះយើងចេញពីអំពើបាបរបស់យើងប៉ុណ្ណោះនោះទេ តែទ្រង់ថែមទាំងសង្គ្រោះយើងចេញពីភាពភាន់ច្រលំទៀតផង។ នៅក្នុងជំពូក២ សាវកប៉ុលបានជួយពួកកូរិនថូសទាំងអស់នេះ ឲ្យបានយកព្រះគ្រីស្ទធ្វើជាចំនុចកណ្តាលក្នុងជីវិត យកព្រះគម្ពីរធ្វើជាគ្រឹះរបស់ពួកគេ ដែលនោះគឺជាវិធីដ៏ល្អបំផុតសំរាប់គ្រីស្ទបរិស័ទគ្រប់រូបឈានឆ្ពោះទៅមុខ។

The above is an abridged translation of "Who has discernment?" by Simon Manchester. If you wish to hear the original English sermon, please go to http://thegospelcoalition.org/resources/entry/who_has_discernment